

ប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី នាពេលកន្លងមក

មន្ត្រីជាន់ខ្ពស់គណបក្សសង្គ្រោះជាតិឲ្យដឹងថា លោក សម រង្ស៊ី បានចាកចេញពីប្រទេសកម្ពុជាទៅប្រទេសបារាំងនៅយប់ថ្ងៃអង្គារនេះ ដោយអះអាងថា ដើម្បីជួបសំណេះសំណាលជាមួយសមាជិកបក្សរបស់ខ្លួន និងប្រាប់ពីស្ថានការនយោបាយនៅកម្ពុជា។

ការចេញដំណើររបស់មេដឹកនាំបក្សប្រឆាំងរូបនេះ ធ្វើឡើងបន្ទាប់ពីតុលាការបានសម្រេចផ្តន្ទាទោសសកម្មជន និងមន្ត្រីបក្សរបស់ខ្លួនចំនួន១១នាក់ឲ្យជាប់ពន្ធនាគារចន្លោះពី៧ឆ្នាំទៅ២០ឆ្នាំ ពីបទដឹកនាំនិងចូលរួមក្នុងចលនាកុប្បកម្មនាំឲ្យមានហិង្សានៅក្បែរទីលានប្រជាធិបតេយ្យកាលពីឆ្នាំ២០១៤។

អ្នកនាំពាក្យគណបក្សសង្គ្រោះជាតិលោក យ៉ែម បុញ្ញឫទ្ធិ ប្រាប់វីអូឌី(VOD)ថា លោក សម រង្ស៊ី បានចាកចេញពីកម្ពុជាទៅប្រទេសបារាំងនៅវេលាម៉ោងប្រមាណ៨យប់ថ្ងៃទី២១ ខែកក្កដានេះ។ តែលោកថា ការចេញទៅក្រៅប្រទេសនេះធ្វើឡើងតាមគម្រោងដែលបានរៀបចំជាយូរណាស់មកហើយ គឺដើម្បីជួបសំណេះសំណាលជាមួយអ្នកគាំទ្ររបស់ខ្លួនប្រាប់ពីស្ថានភាពនយោបាយនៅកម្ពុជា និងប្រាប់ពីដំណើរការនៃទូរទស្សន៍ព្រះអាទិត្យ។

យ៉ាងណាក៏ដោយលោក យ៉ែម បុញ្ញឫទ្ធិ សម្តែងការសោកស្តាយចំពោះចំណាត់ការរបស់តុលាការដែលបានផ្តន្ទាទោសសកម្មជន និងមន្ត្រីបក្សរបស់ខ្លួន ដោយចាត់ទុកថា ចំណាត់របស់តុលាការមិនឆ្លុះបញ្ចាំងតាមនីតិវិធីច្បាប់។ បើតាមអ្នកនាំពាក្យរូបនេះ គណបក្សសង្គ្រោះជាតិនឹងរកមេធាវីបន្ថែមទៀត ដើម្បីការពាររឿងក្តីនេះ ចំណែកមេធាវីមួយចំនួនទៀត លោកថាកំពុងសិក្សាពីនីតិវិធីច្បាប់ ដើម្បីដោះស្រាយបញ្ហានេះ។

គួរបញ្ជាក់ថា បន្ទាប់ពីបានបើកសវនាការអស់ពេញមួយថ្ងៃនៅថ្ងៃនេះ ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញបានអានសាលក្រមសម្រេចផ្តន្ទាទោសលោក មាជ សុវណ្ណារ៉ា លោក អឿ ណារិទ្ធិ និងលោក ឃិន ជំរឿន ឲ្យជាប់ពន្ធនាគារម្នាក់២០ឆ្នាំ ពីបទដឹកនាំកុបកម្ម ចំណែកសកម្មជន៨នាក់ផ្សេងទៀតត្រូវជាប់ទោសម្នាក់៧ឆ្នាំពីបទចូលរួមក្នុងចលនាកុប្បកម្មនាំឲ្យមានហិង្សនៅក្បែរទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤។

តុលាការក៏បានសម្រេចឲ្យសកម្មជនទាំង១១នាក់ត្រូវរួមគ្នាផ្តល់ប្រាក់សំណងរដ្ឋប្បវេណីទៅដើមបណ្តឹងជាសន្តិសុខខណ្ឌដូនពេញចំនួន៣៩នាក់ចាប់ពី៨លានរៀល ដល់២០លានរៀលផងដែរ។ សកម្មជនទាំង១១នាក់ត្រូវបានបញ្ជូនខ្លួនទៅពន្ធនាគារព្រៃសបន្ទាប់ពីសវនាការ។

គួររំឭកថា  ក្រោយហិង្សាក្បែរទីលានប្រជាធិបតេយ្យកាលពីឆ្នាំ២០១៤ លោក មាជ សុវណ្ណារ៉ា និងសកម្មជនគណបក្សសង្គ្រោះជាតិមួយចំនួនទៀតត្រូវបានអាជ្ញាធរចាប់ខ្លួន។ នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៥ មុនចូលឆ្នាំខ្មែរ លោក មាជ សុវណ្ណារ៉ា និងសកម្មជនគណបក្សសង្គ្រោះជាតិទាំងនោះត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងប្រធានគណបក្សសង្គ្រោះជាតិលោក សម រង្ស៊ី បានជួបចរចាគ្នានៅពេលដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេចចេញជារូបរាង៕

សូមសរសេរមកលោក ឡាយ សាមាន តាមរយៈ samean@vodhotnews.com